# កិច្ចសន្ទនាអន្តរសាសនាអន្តរជាតិលើកទី៨
# រវាងពុទ្ធសាសនា និងគ្រីស្តសាសនា
## ក្រោមប្រធានបទ
# "ពុទ្ធបរិស័ទនិងគ្រីស្តបរិស័ទ រួមគ្នារក្សាសុខដុមនីយកម្មសាសនាដោយភាពអត់ធន់"
## នៅព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ
## (ថ្ងៃទី២៦ ដល់ ៣០ ខែឧសភា ឆ្នាំ២០២៥)

**I-សេចក្តីផ្តើម**

នៅក្នុងសេចក្តីប្រកាសចំណងជើងថា ***នៅសម័យកាលយើង*** (***Nostra Aetate***) ឆ្នាំ១៩៦៥ ព្រះសហគមន៍កាតូលិកបានសម្តែងចេញនូវការគោរពយ៉ាងជ្រាលជ្រៅចំពោះសាសនានានា ជាពិសេសបានទទួលស្គាល់នូវមាគ៌ាព្រហ្មចរិយធម៌ដ៏ប្រពៃក្នុងការ "រំដោះជីវិតឱ្យរួចផុតពីសេចក្តីទុក្ខ" នៅក្នុងព្រះពុទ្ធសាសនា និងរឮកដឹងថាជីវិតគឺមិនទៀងទាត់ និងជាទុក្ខនៅក្នុងពិភពលោកនេះ។ ស្របតាមទស្សនវិស័យនេះ ក្រសួងវ៉ាទីកង់សម្រាប់កិច្ចសន្ទនាអន្តរសាសនា បានផ្តួចផ្តើមនិងបន្តគាំទ្រកិច្ចសន្ទនារវាងពុទ្ធសាសនានិងគ្រីស្តសាសនា ដែលធ្វើឡើងជាហូរហែដើម្បីផ្តល់មធ្យោបាយស្វែងយល់ និងសហប្រតិបត្តិការគ្នាទៅវិញទៅមក។

កិច្ចសន្ទនាអន្តរសាសនារវាងពុទ្ធសាសនានិងគ្រីស្តសាសនា ណែនាំឱ្យពុទ្ធបរិស័ទ និងគ្រីស្តបរិស័ទទាំងព្រះសង្ឃ លោកបូជាចារ្យ ក្រុមបងប្រុសបងស្រី អ្នកសិក្សា និងអ្នកគោរពប្រណិប័តន៍សាសនារួមគ្នារិះគិតអំពីជីវិតផ្លូវវិញ្ញាណ និងគុណតម្លៃសីលធម៌។ នៅក្នុងកិច្ចសន្ទនាអន្តរសាសនារវាងពុទ្ធសាសនា និងគ្រីស្តសាសនានេះ អ្នកចូលរួមទាំងអស់ស្វែងរកសេចក្តីដែលមាននៅក្នុងប្រពៃណីសាសនាទាំងពីរ ដែលអាចជួយព្យាបាលរបួសសង្គម ស្តារគុណតម្លៃមនុស្ស និងកសាងយុត្តិធម៌និងមេត្តាធម៌នៅក្នុងពិភពលោកមួយដែលពោរពេញដោយអំពើហិង្សា និងការបែកបាក់គ្នា។

ចាប់តាំងពីការបង្កើតទំនាក់ទំនងការទូតឡើងវិញរវាងព្រះរាជាណាចក្រកម្ពុជា និងសន្តអាសនៈក្នុងឆ្នាំ ១៩៩៤ បន្ទាប់ពីការបញ្ចប់សង្គ្រាមស៊ីវិលជាច្រើនទសវត្សរ៍ ហើយឈានទៅរកសន្តិភាពពេញលេញនៅក្នុងប្រទេសកម្ពុជា។ ព្រះសហគមន៍កាតូលិកកម្ពុជាបានដើរតួនាទីយ៉ាងសកម្ម និងចូលរួមស្ថាបនា ក្នុងការផ្សះផ្សាជាតិ ការអភិវឌ្ឍន៍សង្គម និងការសន្ទនាអន្តរសាសនា។ ជាច្រើនឆ្នាំមកនេះ ព្រះសហគមន៍កាតូលិកនៃប្រទេសកម្ពុជាបានបង្កើតទំនាក់ទំនងដ៏រឹងមាំ និងប្រកបដោយការគោរពជាមួយពុទ្ធសាសនាដែលជាសាសនារបស់រដ្ឋ។ ទំនាក់ទំនងនេះត្រូវបានធ្វើឡើងដោយការផ្លាស់ប្តូរទស្សនកិច្ចជាទៀងទាត់ នៅកម្រិតផ្សេងៗគ្នា រួមទាំងមេដឹកនាំនៃស្ថាប័នសាសនា អង្គការមិនមែនរដ្ឋាភិបាល ក្រុមបុព្វជិតបុព្វជីតា ស្ថាប័នអប់រំគ្រប់កម្រិត។ ការចូលរួមទាំងនេះឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរួមគ្នាបង្កើតសន្តិភាព ការយោគយល់គ្នា និងការលើកកម្ពស់ផលប្រយោជន៍រួម។ ព្រះសហគមន៍កាតូលិក និងពុទ្ធសាសនាបានធ្វើសកម្មភាព និងកិច្ចសហការរួមគ្នា ជាពិសេសក្នុងវិស័យអប់រំ ជំនួយមនុស្សធម៌ និងការអភិវឌ្ឍន៍សហគមន៍ ដែលទាំងអស់នេះបានក្លាយជាស្ពានដ៏សំខាន់នៃមិត្តភាពរវាងអ្នកកាន់សាសនាព្រះពុទ្ធ និងកាតូលិក។ តាមរយៈកិច្ចខិតខំប្រឹងប្រែងទាំងអស់នេះ សាសនាទាំងពីរបន្តបង្ហាញថាភាពសុខដុមរមនាអន្តរជំនឿមិនត្រឹមតែអាចធ្វើទៅបានប៉ុណ្ណោះទេក្នុងប្រទេសកម្ពុជា ថែមទាំងបញ្ជាក់ថាពិតជាមានសារៈសំខាន់សម្រាប់ជួយសង្គមកម្ពុជា និងភាពរីកចម្រើនក្នុងសង្គម។

ព្រះសហគមន៍កាតូលិកនៅកម្ពុជារួមមាន ព្រះសហគមន៍ភូមិភាគភ្នំពេញ ភូមិភាគបាត់ដំបង និងភូមិភាគកំពង់ចាម គឺបានចូលរួមយ៉ាងសកម្ម និងបានអនុវត្តជាក់ស្តែងនៅក្នុងការសន្ទនា និងកិច្ចសហប្រតិបត្តិការអន្តរសាសនារវាងពុទ្ធសាសនា និងកាតូលិកអស់រយៈពេលជាច្រើនឆ្នាំ។ ការប្តេជ្ញាចិត្តនេះត្រូវបានចាក់ឫសយ៉ាងជ្រៅ នៅក្នុងបេសកកម្មរបស់ព្រះសហគមន៍កាតូលិកដើម្បីបង្កើតសន្តិភាព ការផ្សះផ្សា និងការបម្រើដល់មនុស្សទាំងអស់ដោយមិនប្រកាន់នូវជំនឿសាសនា ប៉ុន្តែព្រះសហគមន៍កាតូលិកកម្ពុជានៅតែរក្សាអត្តសញ្ញាណរបស់ខ្លួនក្នុងការប្រកាសដំណឹងល្អក្នុងសង្គមពុទ្ធសាសនា។

## II-**ប្រវត្តិសង្ខេបនៃកិច្ចសន្ទនាអន្តរសាសនាអន្តរជាតិ**

**កិច្ចសន្ទនាអន្តរសាសនារវាងពុទ្ធសាសនានិងគ្រីស្តសាសនានេះបានចាប់ផ្តើមនៅឆ្នាំ១៩៩៥** ដោយការជួបប្រជុំសន្ទនាគ្នាលើកដំបូងនៅកោះតៃវ៉ាន់ក្រោមប្រធានបទអំពី "ភាពប្រសព្វគ្នា និងភាពខុសប្លែកគ្នារវាងពុទ្ធសាសនា និងគ្រីស្តសាសនា" ដែលបានចាក់គ្រឹះឱ្យមានកិច្ចសន្ទនាអន្តរសាសនារវាងពុទ្ធសាសនានិងគ្រីស្តសាសនាបន្តបន្ទាប់ឡើង។ ប្រធានបទក្នុងឆ្នាំកន្លងមកមានដូចជា "ភាពស្ងៀមស្ងាត់និងព្រះបន្ទូល" រៀបចំឡើងនៅប្រទេសឥណ្ឌាឆ្នាំ១៩៩៨ "ជីវិតក្នុងសហគមន៍" រៀបចំឡើងនៅប្រទេសជប៉ុនឆ្នាំ២០០០ "សន្តិភាពក្នុងចិត្តនិងសុខដុមរមនាសកល" រៀបចំឡើងនៅទីក្រុងរ៉ូមឆ្នាំ២០១៣ "ភាតរភាព" រៀបចំឡើងនៅប្រទេសឥណ្ឌាឆ្នាំ២០១៥ និង "មាគ៌ាអហិង្សា" រៀបចំឡើងនៅកោះតៃវ៉ាន់ឆ្នាំ២០១៧

បានបង្កើតឱ្យមានការសន្ទនាគ្នារវាងអ្នកចូលរួមពីសាសនាទាំងពីរយ៉ាងស្និទ្ធស្នាល។ ក្រោយវិបត្តិជំងឺរាតត្បាតកូវីដ១៩ កិច្ចសន្ទនាអន្តរសាសនារវាងពុទ្ធសាសនានិងគ្រីស្តសាសនាលើកទី៧ បានធ្វើឡើងនៅទីក្រុងបាងកកឆ្នាំ២០២៣ ដោយផ្តោតលើប្រធានបទ "កិច្ចសន្ទនាដោយសេចក្តីករុណា និងសេចក្តីស្រឡាញ់ដើម្បីព្យាបាលរបួសមនុស្សលោក និងភពផែនដី" សង្កត់ធ្ងន់លើមេត្តាធម៌ សេចក្តីស្រឡាញ់ និងការព្យាបាលបរិស្ថានក្រោយសម័យជំងឺកូវីដក្នុងពិភពលោក។

## III-គោលបំណងនៃកិច្ចសន្ទនាអន្តរសាសនាអន្តរជាតិលើកទី៨

កិច្ចសន្ទនាអន្តរសាសនាអន្តរជាតិលើកទី៨ រវាងពុទ្ធសាសនា និងគ្រីស្តសាសនា នឹងប្រព្រឹត្តទៅនៅទីក្រុងភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីបន្តដំណើរការសន្ទនាក្រោមប្រធានបទ "**ពុទ្ធបរិស័ទនិងគ្រីស្តបរិស័ទរួមគ្នាកសាងសន្តិភាពតាមរយៈការសម្រុះសម្រួលនិងភាពអត់ធន់**"។ កិច្ចសន្ទនាអន្តរសាសនានេះមានបំណងស្វែងយល់អំពីគ្នាទៅវិញទៅមកឱ្យបានស៊ីជម្រៅ និងថ្លឹងថ្លែងអំពីខ្លឹមសារនៃសាសនាទាំងពីរស្របតាមព្រះបន្ទូល ព្រះធម៌ និងសក្ខីភាពក្នុងជីវិតរស់នៅ ដើម្បីឆ្លើយតបទៅនឹងរបួសយ៉ាងជ្រៅនៃពិភពលោករបស់យើងតាមរយៈការព្យាបាល ភាពអត់ធន់ និងការប្តេជ្ញាចិត្តរួមគ្នាក្នុងការកសាងសន្តិភាព។

លើសពីនេះ បរិបទកម្ពុជាបានធ្វើឱ្យកិច្ចសន្ទនានេះកាន់តែមានអត្ថន័យជ្រាលជ្រៅពិសេសបន្ថែមទៅទៀត។ ជីវិត និងស្នាព្រះហស្តរបស់សម្តេចព្រះមហាឃោសានន្ទជាព្រះសង្ឃមួយអង្គដែលមានព្រះកិត្តិនាមល្បីល្បាញជា "មហាត្មៈគន្ធីកម្ពុជា" ជានិមិត្តរូបនៃអំពើអហិង្សាដ៏មានអនុភាព និងអំពីភាពអត់ធន់ខាងផ្លូវវិញ្ញាណនៅចំពោះមុខទុក្ខលំបាកដ៏សែនជ្រៅ។ សេចក្តីបង្រៀនដ៏មានអត្ថន័យរបស់ព្រះអង្គតាមរយៈ *ដំណើរធម្មយាត្រា* (ដំណើរសន្តិភាព) បន្តណែនាំការខិតខំអន្តរជំនឿរបស់យើងក្នុងការកសាងសន្តិភាព មេត្តាធម៌ និងការសម្រុះសម្រួល។

## IV-សកម្មភាពនៃកិច្ចការសម្រាប់សន្តិភាព និងការផ្សះផ្សា

សម្លេងដើម្បីសន្តិភាពមួយទៀតរបស់ប្រទេសកម្ពុជា គឺលោក **ទុន ចាន់ណារេត** ដែលជាសកម្មជនកាតូលិក និងជាអ្នកដែលបានទទួលពានរង្វាន់ណូបែលសន្តិភាពឆ្នាំ១៩៩៧ ក្នុងយុទ្ធនាការអន្តរជាតិដើម្បីលុបបំបាត់គ្រាប់មីន។ **បងស្រី ដឹនីស កូឡាន** ជាសហការីរបស់លោក និងជាអ្នកណែនាំមណ្ឌលមេត្តាករុណានៅខេត្តសៀមរាប នឹងចែករំលែកអំពីដំណើរជីវិតរបស់លោកចេញពីអ្នករងគ្រោះដោយសារគ្រាប់មីនរហូតក្លាយជាអ្នកតស៊ូមតិជាសាកលដើម្បីសន្តិភាពនិងការរំសាយសព្វាវុធ។

ដើម្បីបញ្ជាក់នៃការប្តេជ្ញាចិត្តចំពោះកិច្ចការសន្តិភាពក្នុងអន្តរសាសនានេះ ព្រះសហគមន៍កាតូលិកកម្ពុជា បានចូលជាសមាជិកសកម្មនៅក្នុងក្រុមប្រឹក្សាអន្តរសាសនាកម្ពុជា (C.I.C.) ដែលជាវេទិកាមួយប្រមូលផ្តុំមេដឹកនាំមកពីសាសនាផ្សេងៗដើម្បីជំរុញការយល់ដឹង ឯកភាព និងកិច្ចសហប្រតិបត្តិការ។ តាម

រយៈក្រុមប្រឹក្សាអន្តរសាសនាកម្ពុជា មេដឹកនាំ ក៏ដូចជាគ្រីស្តបរិស័ទពីព្រះសហគមន៍កាតូលិកទាំងបីភូមិភាគបានចូលរួមជាទៀងទាត់នៅក្នុងការសន្ទនាអន្តរជំនឿ ការពិភាក្សាអំពីគំនិតផ្តួចផ្តើមកសាងសន្តិភាពរួមគ្នា និងព្រឹត្តិការណ៍ផ្សេងៗដែលលើកកម្ពស់ភាពសុខដុមរមនា និងការផ្សះផ្សាក្នុងចំណោមសហគមន៍អន្តរសាសនានៅក្នុងប្រទេសកម្ពុជា។

កិច្ចសហការដ៏ល្អស៊ីសង្វាក់គ្នា និងស្មោះត្រង់ចំពោះគ្នាទៅវិញទៅមកក្នុងចំណោមអន្តរសាសនានៅកម្ពុជា ជាពិសេសទំនាក់ទំនងជិតស្និទ្ធ និងភាតរភាពក្នុងចំណោមអ្នកកាន់សាសនាកាតូលិក និងពុទ្ធសាសនា ត្រូវបានមើលឃើញកាន់តែច្បាស់ថាជាគំរូនៃភាពសុខដុមរមនារវាងសាសនាក្នុងប្រទេសកម្ពុជា។ ជាក់ស្តែងណាស់ ក្នុងពេលដែលជម្លោះសាសនានៅតែបន្តកើតមានឡើងជាច្រើនករណីនៅក្នុងពិភពលោក ប្រទេសកម្ពុជាគួរតែឈរជាសាក្សី ក្នុងការសន្ទនាអន្តរសាសនា ការគោរពគ្នាទៅវិញទៅមក និងការរួមគ្នាបម្រើសង្គមសម្រាប់ការកសាងសន្តិភាព និងការផ្សះផ្សាយូរអង្វែង។

ព្រះសហគមន៍កាតូលិកនៅកម្ពុជា នៅតែប្តេជ្ញាចិត្តយ៉ាងពេញលេញក្នុងការធ្វើដំណើររួមគ្នាជាមួយនិងសាសនាទាំងអស់មិនត្រឹមតែតាមរយៈពាក្យសម្តី ឬឯកសារប៉ុណ្ណោះទេ ប៉ុន្តែតាមរយៈសកម្មភាពជាក់ស្តែងនៃការស្វែងរកយុត្តិធម៌ សន្តិភាព និងសេចក្តីស្រឡាញ់ក្នុងសង្គមកម្ពុជា។ ដំណើររួមគ្នានេះបន្តបំផុសក្តីសង្ឃឹម និងការរួបរួមក្នុងប្រទេសកម្ពុជា និងផ្តល់នូវគំរូលើកទឹកចិត្តសម្រាប់ទំនាក់ទំនងអន្តរសាសនាទូទាំងពិភពលោក។

ក្នុងស្មារតីជំរុញកិច្ចសន្ទនាប្រកបដោយការគោរព និងសាមគ្គីភាពខាងផ្លូវវិញ្ញាណ កិច្ចសន្ទនាអន្តរសាសនាអន្តរជាតិលើកទី៨ រវាងពុទ្ធសាសនានិងគ្រីស្តសាសនា សូមគោរពអញ្ជើញសមាជិកសមាជិកាទាំងអស់ធ្វើការប្តេជ្ញាចិត្តឡើងវិញ ដើម្បីកសាងសន្តិភាព និងពង្រឹងកិច្ចសហប្រតិបត្តិការអន្តរសាសនាដើម្បីកសាងពិភពលោកមួយដែលកាន់តែប្រសើរឡើង។

*ភ្នំពេញ ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៥*